**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ ៦២៨ ស.ភ.រ

# សេចក្តីណែនាំ

# ដល់បេក្ខជនក្នុងពេលប្រឡង

បេក្ខជនទាំងពីរភេទចូលរួមប្រឡងប្រជែងចូលរៀនជាសិស្សមន្ត្រីក្រមការលើកទី៧ នៅសាលាភូមិន្ទរដ្ឋបាល ត្រូវគោរពអនុវត្តតាមការណែនាំដូចតទៅៈ

- ត្រូវចូលមកមណ្ឌលប្រឡងតាមច្រកទ្វារខាងក្រោយ និងយកភ្ជាប់មកជាមួយនូវសលាកបត្រឯកត្តជន អត្តសញ្ញាណបណ្ណ ឬលិខិតសំគាល់ខ្លួន ព្រមទាំង ប៊ិចខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង
- ហាមយកជាប់ជាមួយនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។ សាលាមិនទទួលខុសត្រូវ រក្សាទុកនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" ត្រូវសុំការអនុញ្ញាតពីប្រធានមណ្ឌលប្រឡងជាមុនទើបអាចចូលប្រឡងបាន និងប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវលើស "១៥ នាទី" មិនអនុញ្ញាតឲ្យចូលប្រឡងដាច់ខាត។
- អវត្តមានមិនបានប្រឡងវិញ្ញាសាណាមួយ នឹងមិនត្រូវបានអនុញ្ញាតឲ្យប្រឡងវិញ្ញាសាបន្តបន្ទាប់ឡើយ។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាលសន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញទោះបីជាក្រដាសប្រឡងគ្មានសរសេរចម្លើយ ឬដំណោះស្រាយអ្វីក៏ដោយ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឲ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការប្រឡងឡើយ។ មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព ប៉ុនប៉ងលួចចម្លង ឬចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាកណ្តឹងៈ
  + កណ្តឹងទី១ៈ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
  + កណ្តឹងទី២ៈ ចាប់ផ្តើមធ្វើវិញ្ញាសា
  + កណ្តឹងទី៣ៈ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
  + កណ្តឹងទី៤ៈ ប្រគល់សន្លឹកកិច្ចការប្រឡងឲ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំនានានេះ ឬគំរាមកំហែង ឬធ្វើឲ្យប៉ះពាល់ដល់កិត្តិយស បូរណភាពរូបរាងកាយមន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឲ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តនេះ និងហាមឃាត់មិនឲ្យចូលរួមប្រឡងប្រជែងនៅសាលាភូមិន្ទរដ្ឋបាលជាអចិន្ត្រៃយ៍ ព្រមទាំងទទួលខុសត្រូវតាមវិធានច្បាប់ជាធរមាន។

គណៈមេប្រយោគ មានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឲ្យបាននូវភាពរលូននៃដំណើរការប្រឡងរបស់បេក្ខជន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ ៨

**គណៈមេប្រយោគ**

**ប្រធាន**

**ពេជ្រ ប៊ុនធិន**